# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

<u>សេចក្តីប្រកាសពត៌មាន</u>

# ខួបម្ភៃឆ្នាំ នៃកម្មវិធីអាហារូបករណ៍អូស្ត្រាលីនៅប្រទេសកម្ពុជា

អ្នកជំនួញលំដាប់កំពូល មន្ត្រីរដ្ឋាភិបាល បញ្ញាវន្ត និងថ្នាក់ដឹកនាំនៃអង្គការសង្គមស៊ីវិលមួយចំនួននៅប្រទេសកម្ពុជា នឹងប្រារព្ធពិធីអបអរខួបលើកទី២០ នៃកម្មវិធីអាហារូបករណ៍អូស្ត្រាលីនៅកម្ពុជា នាពាត្រីនេះ។

ក្នុងរយៈពេលជាងពីរទសវត្សកន្លងមក មាននិស្សិតឆ្នើមកម្ពុជាចំនួនច្រើនជាង ៥០០នាក់ បានទទួលអាហារូបករណ៍ពីរដ្ឋាភិបាលអូស្ត្រាលី ដើម្បីទៅសិក្សានៅប្រទេសអូស្ត្រាលី។ ក្រៅពីនេះ ក៏មានសិស្សនិស្សិតចំនួនច្រើនជាងនេះផ្សេងទៀត ដែលបានសិក្សានៅប្រទេសអូស្ត្រាលីជាលក្ខណៈឯកជន ឬក្រោមកម្មវិធីអាហារូបករណ៍ដទៃទៀត។

ការប្រារព្ធពិធីអបអរខួបនេះ នឹងប្រមូលផ្តុំជាលើកទីមួយនូវអតីតសិស្សនិស្សិតដែលបានបញ្ចប់ការសិក្សាពីប្រទេសអូស្ត្រាលី ដោយផ្តល់នូវឱកាសសំរាប់ចែករំលែកនូវអនុស្សាវរីយ៍ អបអរដល់ភាពជោគជ័យ និងផ្សាភ្ជាប់ទំនាក់ទំនងងថ្មីៗបន្ថែមទៀត។

លោកជំទាវ **អាលីសុន បើរ៉ូ (Alison Burrows)** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា ការរំលឹកខួបនេះគឺជាឱកាសមួយដើម្បីរំលឹកនូវការចូលរួមរបស់ពួកគេក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា។

លោកជំទាវមានប្រសាសន៍ថា «អតីតនិស្សិតដែលបានបញ្ចប់ការសិក្សាពី ប្រទេសអូស្ត្រាលីបានក្លាយជា រដ្ឋមន្ត្រី ឯកអគ្គរាជទូត មន្ត្រីជាន់ខ្ពស់ ប្រធានក្រុមហ៊ុន ព្រឹទ្ធបុរសប្រចាំសកលវិទ្យាល័យ និងអ្នកដឹកនាំតាមសហគមន៍។»

«ខ្ញុំមានមោទនភាពដោយបានឃើញនូវការចូលរួមរបស់អូស្ត្រាលី នៅក្នុងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា តាមរយៈការបណ្តុះបណ្តាលសិស្សនិស្សិតឆ្នើមមកពីគ្រប់ស្រទាប់សង្គម។»

ការសិក្សានៅប្រទេសអូស្ត្រាលី គឺជាបទពិសោធន៍មួយដែលផ្លាស់ប្តូរអនាគតរបស់សិស្សនិស្សិតកម្ពុជាជាច្រើន។

អ្នកស្រី ទុំ ស៊ីសុភារ៉េត បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកអប់រំ នៅសកលវិទ្យាល័យ Flinders តាមរយៈកម្មវិធីអាហារូបករណ៍អូស្ត្រាលីក្នុងឆ្នាំ២០០៤។ បច្ចុប្បន្នគាត់កំពុងបម្រើ

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

ការជាអ្នកសម្របសម្រួលថ្នាក់ខេត្តរបស់អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយ និងជាអ្នកបណ្តុះបណ្តាលគ្រូបង្គោលនៅក្នុងខេត្តកំពង់ចាម។ នេះគឺជាជោគជ័យដ៏ធំធេងចំពោះក្មេងស្រីតែម្នាក់គត់ដែលបានរៀនបញ្ចប់មធ្យមសិក្សាប្រចាំភូមិរបស់នាងក្នុងឆ្នាំនោះ។

បើតាមលោក អៀង ប៊ុនថន ប្រធានសមាគមអតីតនិស្សិតមកពីប្រទេសអូស្ត្រាលីប្រចាំនៅកម្ពុជា និងជាអតីតនិស្សិតនៃសកលវិទ្យាល័យជាតិអូស្ត្រាលី ការឆ្លុះបញ្ចាំងអោយឃើញពីផលប្រយោជន៍នៃការអប់រំនៅប្រទេសអូស្ត្រាលីគឺមានយ៉ាងពិតប្រាកដ។

«អ្វីៗទាំងអស់គឺស្ថិតនៅត្រង់គុណភាព ពោលគឺទាំងសាស្ត្រាចារ្យ បរិក្ខាសិក្សានិងការរស់នៅ។»

លោក អៀង ប៊ុនថនបានមានប្រសាសន៍ថា «ហើយលទ្ធផលទាំងនេះមិនបានបញ្ចប់នៅត្រឹមពេលដែលអ្នកចាកចេញពីប្រទេសអូស្ត្រាលីនោះទេ បណ្តាញអតីតនិស្សិតសិក្សានៅប្រទេសអូស្ត្រាលី គឺជាប្រភពដ៏ធំមួយសំរាប់ការប្រឹក្សា និងការគាំទ្រនានា។»

និស្សិតជាច្រើនរូបបានត្រលប់មកកាន់មាតុប្រទេសវិញ ដោយពាំនាំមកជាមួយនូវគំនិតថ្មីៗដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍នៅកម្ពុជា តាមរយៈការចូលរួមក្នុង ជួររដ្ឋាភិបាល សង្គមស៊ីវិល រឺក្នុងវិស័យឯកជន។ បទពិសោធន៍ពីការសិក្សានៅប្រទេសអូស្ត្រាលី បានជំរុញទឹកចិត្ត លោក ចាង ប៊ុនលាង អោយចូលរួមបង្កើតហាងកាហ្វេប្រោន នៅទីក្រុងភ្នំពេញ។

លោក ប៊ុនលាង មានប្រសាសន៍ថា «ការសិក្សានៅប្រទេសអូស្ត្រាលី បានផ្តល់នូវមូលដ្ឋានគ្រឹះនិងបង្កើនចំនេះដឹងដល់ខ្ញុំក្នុងការចូលរួមអភិវឌ្ឍនៅកម្ពុជា។ វប្បធម៌នៃការនិយមកាហ្វេយ៉ាងខ្លាំងនៅទីក្រុងស៊ីដនីនិងមែលប៊ន បានជំរុញទឹកចិត្ត និងផ្តល់ជាគំនិតអោយខ្ញុំក្នុងការបង្កើតហាងកាហ្វេប្រោននេះឡើង។ អូស្ត្រាលីបានបើកចំហរពិភពដ៏តូចចង្អៀតរបស់ខ្ញុំ ដើម្បីចាប់នូវឱកាសយ៉ាងច្រើនដែលមិនអាចរៀបរាប់អស់បាន។»

អូស្ត្រាលីកំពុងក្លាយជាគោលដៅដ៏មានប្រជាប្រិយសំរាប់និស្សិតកម្ពុជា រួមទាំងការសិក្សាជាលក្ខណៈឯកជន និងតាមរយៈការសិក្សាពីចំងាយ ។ ក្នុងឆ្នាំ២០១៣ មាននិស្សិតកម្ពុជាច្រើនជាង៦០០នាក់ដែលបានទៅសិក្សាតាមថ្នាក់ឧត្តមសិក្សានៅប្រទេសអូស្ត្រាលី។

សំរាប់ពត័មានបន្ថែមអំពីកម្មវិធីអាហារូបករណ៍អូស្ត្រាលី សូមមើល http://australiaawardscambodia.org/។

**ទំនាក់ទំនងពត៌មាន៖ លោក សាយម៉ុន ហ្វ៊ៀលឡូវ លេខាទី១ ស្ថានទូតអូស្ត្រាលីភ្នំពេញ**

**ទូរស័ព្ទលេខ ០២៣ ២១៣ ៤៧០**

**ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤**